វេជ្ជបណ្ឌិត សុវត្ថិភាព



## វេជ្ជបណ្ឌិត សុវត្ថិភាព

# តើខ្ញុំគួរលេបថ្នាំនេះទេ?

Should I Take This Medicine_MIOLO.indd 1 19/09/2024 19:06:38

តើខ្ញុំគួរលេបថ្នាំនេះទេ?

**ISBN978-65-87107-65-3**

ក្រុមសម្រង់ Lais Junqueira, Cristiane Tavares, Tiago Dalcin, Helen Haskell, Hussain Jafri, Regina Kamoga.

រូបភាព: Pedro de Luna

ប្លង់សៀវភៅ និងការរចនា: Isabel Freire
Elsevier Foundation: Ylann Schemm, Domiziana Francescon and Maha Rhannam

អ្នកគ្រប់គ្រងគម្រោង: Lais Junqueira

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង: The Elsevier Foundation https://elsevierfoundation.org/
World Patients Alliance https://www.worldpatientsalliance.org

សម្រាប់ទាក់ទងអ្នកគូសរូប សូមសរសេរទៅ Ilustrecomunicacao@gmail.com

តើខ្ញុំគួរលេបថ្នាំនេះទេ?

2024 by Elsevier Foundation and World Patients Alliance
មានអាជ្ញាប័ណ្ណតាម CC BY-NC-ND 4.0
ដើម្បីមើលច្បាប់អាជ្ញាប័ណ្ណនេះ សូមចូលទៅកាន់: https://creativecommons.org/licenses/by-nc-nd/4.0/

មូលនិធិអែលសេវៀរ(Elsevier)និងសម្ព័ន្ធអ្នកជំងឺពិភពលោកបានសហការគ្នាដើម្បីចេញផ្សាយសៀវភៅមួយសម្រាប់កុមារដែលស្តែងអំពីសុវត្ថិភាពអ្នកជំងឺ។

យុទ្ធនាការនេះមានគោលបំណងលើកកម្ពស់ចំណេះដឹងសុខភាពរបស់កុមារតាមសាលាដោយណែនាំពួកគេអំពីគំនិតមូលដ្ឋាននិងគោលការណ៍សុវត្ថិភាពអ្នកជំងឺដោយផ្តល់ការអប់រំដល់អ្នកអានវ័យក្មេងសៀវភៅនេះមានបំណងបង្កើតជំនាន់មួយដែលមានតម្លៃនិងអនុវត្តការថែរក្សាសុខភាពដោយមានសុវត្ថិភាព។លើសពីនេះទៀតនៅពេលដែលកុមារចែករំលែកចំណេះដឹងថ្មីរបស់ពួកគេជាមួយគ្រួសារយុទ្ធនាការនេះសង្ឃឹមថានឹងបង្កើតឥទ្ធិពលវិជ្ជមានយូរអង្វែងលើសហគមន៍ដោយបណ្តុះសមត្ថភាពឱ្យមនុស្សគ្រប់រូបយកសុវត្ថិភាពអ្នកជំងឺជាអាទិភាពនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

Should I Take This Medicine_MIOLO.indd 3 19/09/2024 19:06:38

វាជាថ្ងៃនារដូវផ្ការីកហើយនៅឧទ្យានគឺពោរពេញទៅដោយ
កុមារជាច្រើនទៅលេងបន្ទាប់ពីពួកគេចេញពីរៀន។

អាលី និង ហាមេយ
កំពុងតែសប្បាយរីករាយនៅលើទោងយោល។





Should I Take This Medicine_MIOLO.indd 4 19/09/2024 19:06:38



ភ្លាមនោះ អាលីឈប់សើច
ហើយគាត់ស្រែកថ្ងូរ៖

- អូយ, ហាមេយ!

ក្រពះរបស់ខ្ញុំឈឺខ្លាំងណាស់។

ភ្លាមៗនោះ ហាមេយ
ក៏រត់ទៅផ្ទះរបស់គាត់ដើម្បី
ទៅយកថ្នាំមកជួយមិត្ត
របស់គាត់។



Should I Take This Medicine_MIOLO.indd 5 19/09/2024 19:06:38

នៅក្នុងទូដាក់ថ្នាំរបស់ម៉ាក់ហាមេយ

ហាមេយ
រកឃើញថ្នាំដែលម្ដាយរបស់គាត់
ធ្លាប់ឱ្យគាត់នៅពេលគាត់ឈឺ
បន្ទាប់មកគាត់ក៏យកថ្នាំនោះ
ហើយរត់ទៅរកអាលីវិញ។





Should I Take This Medicine_MIOLO.indd 6 19/09/2024 19:06:39

– អាលី, លេបថ្នាំនេះទៅ! កាលខ្ញុំលេបថ្នាំនេះ
ខ្ញុំបានជាសាយស្បើយ, បើឯងលេប ឯងប្រាកដជា ជាដែរ!

ភ្លាមៗនោះ
ពួកគេក៏ភ្ញាក់ផ្អើលដោយសារតែមានភ្លើងពណ៌បៃតងមួយភ្លឺឡើង។





–   ឈប់សិនអាលី,
កុំលេបថ្នាំនោះអី!

- បងជាអ្នកណា????

– ខ្ញុំគឺជាដុកទ័រ សេហ្វធី ហើយខ្ញុំមកទីនេះដើម្បីជួយឯង
ដោយសារតែហាមេយលេបថ្នាំនេះជា
មិនប្រាកដថាឯងនឹងជាដូចហាមេយទេ។





Should I Take This Medicine_MIOLO.indd 8 19/09/2024 19:06:39

ការឈឺក្រពះអាចកើតឡើងដោយសារហេតុផលផ្សេងៗគ្នា ហើយនោះជាមូលហេតុដែលប្អូនគួរតែសុំឱ្យមនុស្សធំ ឬវេជ្ជបណ្ឌិតដើម្បីជួយប្អូន។
ពួកគាត់អាចផ្តល់ឱ្យប្អូននូវថ្នាំដែលត្រឹមត្រូវ និងប្រាប់ប្អូនថាតើត្រូវទទួលទានថ្នាំអ្វីខ្លះ និងគួរលេបប៉ុន្មានដង!

តើខ្ញុំមិនអាចលេបថ្នាំតែមួយ
ដូចមិត្តភក្តិខ្ញុំបានទេឬ?



– នេះជាសំណួរដ៏ល្អ!
ដោយសារតែយើងគឺជាមនុស្សផ្សេងៗគ្នា
រាងកាយរបស់យើងអាចប្រតិកម្មផ្សេងៗគ្នា
ទៅតាមការប្រើប្រាស់ថ្នាំផងដែរ។ ឧទាហរណ៍,

ការប្រតិកម្មទៅនឹងថ្នាំមួយចំនួន
នេះមានន័យថារាងកាយរបស់ពួកគេ
គឺមិនសមស្របជាមួយថ្នាំទាំងនោះទេ
ហើយវាក៏មានកម្រិតនៃការប្រើប្រាស់
ថ្នាំផ្សេងៗគ្នា

សម្រាប់មនុស្សវ័យផ្សេងៗគ្នាផងដែរ។



– បើដូច្នេះ តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីដឹងថាខ្ញុំគួរប្រើប្រាស់ថ្នាំពេលណា?



– នេះគឺជាឧទាហរណ៍,
តោះយើងទៅមើលទាំង
អស់គ្នា៖







នៅពេលដែលគ្រូពេទ្យប្រាប់ថា
“លេបថ្នាំ២ដង ក្នុង១ថ្ងៃ”
នោះមានន័យថា
យើងគួរតែលេបវាក្នុងរយៈពេល
១២ម៉ោងម្តង។



Should I Take This Medicine_MIOLO.indd 12 19/09/2024 19:06:40







បន្ទាប់មក, នៅពេលគ្រូពេទ្យប្រាប់ថា
“លើបថ្នាំ៣ដង ក្នុង១ថ្ងៃ”
នោះមានន័យថា
យើងគួរតែលេបវាក្នុងរយៈពេល៨ម៉ោងម្តង។






Should I Take This Medicine_MIOLO.indd 13 19/09/2024 19:06:41

- ម្យ៉ាងវិញទៀត ថ្នាំដូចជាអាហារដែលពួកយើងបរិភោគអញ្ចឹង
ពេលខ្លះវាអាចធ្វើឱ្យយើងមិនស្រួលខ្លួនភ្លាមៗ។ ដូច្នេះ
យើងគួរតែពិនិត្យមើលកាលបរិច្ឆេទផុតកំណត់របស់ថ្នាំអោយបានត្រឹម
ត្រូវ មុនពេលប្រើប្រាស់វា
ហើយប្រសិនបើកាលបរិច្ឆេទរបស់ថ្នាំវាហួសថ្ងៃនៅក្នុងប្រតិទិន
យើងមិនគួរប្រើប្រាស់វាទេ។




- នៅពេលភ្លាមនោះ,
ហាមេយបានដឹងថា
ថ្នាំដែលគាត់អោយអាលីគឺ
ផុតកំណត់នៃកាលបរិច្ឆេទ
ហើយគាត់ពិតជាអាម៉ាស់
ដែលគាត់អោយអាលី
នូវថ្នាំដែលផុតកំណត់។

ដុកទ័រសេហ្វធី បាននិយាយបន្ត៖

- យើងមិនគួរចែករំលែកថ្នាំយើង
អោយទៅអ្នកដទៃទេ
ហើយក្មេងៗមិនគួរយកថ្នាំនោះមកប្រើប្រាស់
ដោយខ្លួនឯងទេ
ហើយនេះជាហេតុផល
ដែលថ្នាំគួរតែទុកនៅកន្លែង
ដែលមានសុវត្ថិភាព
នៅផ្ទះ។



អាលី, សួរដោយភាពភ័យខ្លាច៖

–តើខ្ញុំគួរធ្វើបែបណាទៅ? ក្រពះរបស់ខ្ញុំនៅតែឈឺ!

ហាមេឃ ក៏និយាយភ្លាម៖

-នោះម្តាយរបស់ខ្ញុំគឺ
កំពុងមកពីធ្វើការវិញហើយ,
ដុកទ័រសេហ្វធី!ខ្ញុំនិងហាមេឃ
នឹងទៅសុំម្តាយខ្ញុំអោយគាត់ជួយ
ពួកយើង។



ហាមេយ បាននិយាយ៖

- អរគុណ ដុកទ័រសេហ្វធី! ខ្ញុំនឹងអោយថ្នាំនេះទៅម្ដាយរបស់ខ្ញុំ
ដើម្បីបោះវាចោល ហើយចាប់ពីឥឡូវនេះ
ខ្ញុំសូមសន្យាថានឹងអោយតែទឹកទៅអាលីតែប៉ុណ្ណោះ។

– ឈប់!
នៅមានរឿងមួយទៀត!





Should I Take This Medicine_MIOLO.indd 17 19/09/2024 19:06:42

ហាមេឃ និង អាលី
ភ្លាមៗនោះត្រូវបានហ៊ុំព័ទ្ធដោយពន្លឺពណ៌បៃតង។
នៅពេលពួកគេមើលទៅក្រោម ពួកគេកំពុងពាក់ផ្លាកសញ្ញាពណ៌មាស
ជាមួយនិងត្បូងពណ៌បៃតងដ៏ភ្លឺ ដូចដុកទ័រសេហ្វធីបានពាក់ផងដែរ។





Should I Take This Medicine_MIOLO.indd 18 19/09/2024 19:06:42

– ប្អូនទាំងពីរឥឡូវនេះ
ក្លាយជាម្ចាស់ជើងឯកនៃការប្រើប្រាស់ថ្នាំ សុវត្ថិភាព!
យកផ្លាកសញ្ញាថ្នាំសុវត្ថិភាពទាំងនេះ ហើយ
ចូរកុំភ្លេចបង្រៀនអ្នកដទៃអំពីសុវត្ថិភាពនៃការប្រើប្រាស់ថ្នាំ
ឱ្យបានត្រឹមត្រូវណា! សុវត្ថិភាពទាំងអស់គ្នា!



ដោយសារការជួយរបស់ម្ដាយហាមេយ
អាលីទទួលបានថ្នាំដែលគាត់ត្រូវលេបដើម្បីឱ្យក្រពះគាត់បាត់ឈឺ។
ដើម្បីក្លាយជាម្ចាស់ជើងឯកដូច ហាមេយ និង អាលី
យើងគួរតែពិនិត្យមើលកាលបរិច្ឆេទផុតកំណត់របស់ថ្នាំឱ្យបានត្រឹមត្រូវ
លេបថ្នាំតាមការណែនាំរបស់វេជ្ជបញ្ជាគ្រូពេទ្យ ហើយសួរមនុស្សធំ ឬ
មនុស្សចាស់មុនពេលលេបថ្នាំអ្វីមួយ។
តោះ យើងចាប់ផ្ដើមធ្វើវាពីឥឡូវទៅ!!



នាព្រឹកនិទាឃរដូវដ៏ស្ងប់ស្ងាត់មួយសម្រាប់មិត្តភ័ក្តិពីរនាក់គឺ
អាមេដ និង អាលី ត្រូវបានរំខានភ្លាមៗដោយការឈឺពោះរបស់អាលី។
អាមេដ ចង់ជួយនិងផ្តល់ថ្នាំមួយចំនួនពីផ្ទះរបស់គាត់អោយទៅអាលី។
តើនោះជាគំនិតដ៏ល្អបំផុតទេ?

វេជ្ជបណ្ឌិតសុវត្ថិភាពត្រូវចាត់វិធានការឱ្យបានលឿន
ព្រោះយើងមិនគួរចែករំលែកថ្នាំអោយគ្នានោះទេ។

## តើអ្នកធ្លាប់ឈឺពោះទេ?



World Patients Alliance

THE ELSEVIER FOUNDATION

Translated by

KIDSHELP